ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ACCOUNTING AND AUDITING REGULATOR

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ...០៤៣/២៤.....ន. គ. ស .ស.ស.ល.

ថ្ងៃ សុក្រ ១៤រោច ខែ ជេស្ឋ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ,ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការសម្រេចរបស់រាជរដ្ឋាភិបាល

## សម្រាប់សមាជិកសមាគមអ្នកអភិវឌ្ឍន៍លំនៅដ្ឋានកម្ពុជា ក្នុងការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (អ.ស.ហ.) មានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា** សមាជិកសមាគមអ្នកអភិវឌ្ឍន៍លំនៅដ្ឋានកម្ពុជា ជ្រាបថា÷រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចលើវិធានការលើកទឹកចិត្តដល់សមាជិកសមាគមអ្នកអភិវឌ្ឍន៍លំនៅដ្ឋានកម្ពុជា រួមមានដូចខាងក្រោម÷

១. មិនអនុវត្តពិន័យអន្តរការណ៍ ចំពោះសមាជិកសមាគបអ្នកអភិវឌ្ឍន៍លំនៅដ្ឋានកម្ពុជា រហូតដល់ការអនុគ្រោះបង់ពន្ធជាកញ្ចប់ ត្រូវបានបញ្ចប់។

២. ពន្យារពេលការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម ដែលមានបច្ចេកទេសខ្ពស់ និងត្រូវការពេលសិក្សាស្វែងយល់ រួមមាន÷ ១).កាតព្វកិច្ចអនុវត្តស្តង់ដាគណនេយ្យជាធរមាន និង២).កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។

៣. ត្រូវអនុវត្តកាតព្វកិច្ច រួមមាន÷ កាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** ជាកំហិត។

៤. គួរមានឆន្ទៈ និងមានផែនការច្បាស់លាស់ក្នុងការចូលរួមសិក្សា ស្រាវជ្រាវ និងចូលរួមការបណ្តុះបណ្តាលស្តង់ដាបច្ចេកទេស ដែលរៀបចំដោយ **ន.គ.ស.** និងគ្រឹះស្ថានបណ្តុះបណ្តាលដែលមានការទទួលស្គាល់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា** សមាជិកសមាគមអ្នកអភិវឌ្ឍន៍លំនៅដ្ឋានកម្ពុជា ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel
របស់និយ័តករគណនេយ្យនិងសវនកម្ម